ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍បាត់ដំបង

សំណុំរឿងសភាព្រហ្មទណ្ឌលេខ ៦៥
ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០២២

**សាលដីកា**

លេខ ៥៤៧ "ជ"
ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២២

# ក្នុងនាមប្រជារាស្ត្រខ្មែរ
# សាលាឧទ្ធរណ៍បាត់ដំបង

បង្កើតឡើងតាមច្បាប់ស្ដីពីការរៀបចំអង្គការតុលាការ ដែលបានប្រកាសឱ្យប្រើតាម ព្រះរាជក្រម លេខ នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤។

បានបើកសវនាការជាសាធារណៈ នៅសាលសវនាការសាលាឧទ្ធរណ៍បាត់ដំបង នាថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០២២ ដោយមានសមាសភាពដូចខាងក្រោម ៖

17-10-22

សង 128

## សមាសភាពក្រុមប្រឹក្សាជំនុំជម្រះ

លោក [redacted] ប្រធានក្រុមប្រឹក្សា
លោក [redacted] ចៅក្រមប្រឹក្សា
លោក [redacted] ចៅក្រមប្រឹក្សា

## តំណាងមហាអយ្យការ

លោក [redacted] ព្រះរាជអាជ្ញា

## ក្រឡាបញ្ជីសវនាការ

លោកស្រី [redacted] ក្រឡាបញ្ជីសាលាឧទ្ធរណ៍

ដើម្បីជំនុំជម្រះបណ្ដឹងឧទ្ធរណ៍ នៃសំណុំរឿងសភាព្រហ្មទណ្ឌលេខ ៦៥ ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០២២ មានដូចខាងក្រោម ៖

**-ជនជាប់ចោទ ឈ្មោះ** [redacted] សោភា ហៅ មុំ ភេទស្រី អាយុ ៥៥ឆ្នាំ សញ្ជាតិខ្មែរ ជនជាតិខ្មែរ កាន់សាសនាព្រះពុទ្ធ មុខរបរមេផ្ទះ ទីកន្លែងកំណើតកើតនៅឃុំបរវេល ស្រុកបាត់ដំបង ខេត្តបាត់ដំបង ទីលំនៅបច្ចុប្បន្ននៅផ្ទះលេខ ១០សេ ផ្លូវ២៩២ សង្កាត់បឹងកេងកង ខណ្ឌចំការមន រាជធានីភ្នំពេញ ប្ដីឈ្មោះ [redacted] ឪពុកឈ្មោះ [redacted] "រស់" ម្ដាយឈ្មោះ [redacted] "រស់" ទោសពីមុន គ្មាន។ (ក្រៅឃុំ) (ចុងបណ្ដឹងឧទ្ធរណ៍)



Scanned with CamScanner

ជាប់ចោទពីបទៈ ប៉ះពាល់កម្មសិទ្ធិឯកជន និងធ្វើឱ្យខូចដោយចេតនា ប្រព្រឹត្តនៅភូមិព្រៃទទឹង ឃុំគោកខ្ពស់ ស្រុកបន្ទាយអំពិល ខេត្តឧត្តរមានជ័យ កាលពីថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៧ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា ២៤៨ មាត្រា ២៥៣ នៃច្បាប់ភូមិបាល និង មាត្រា ៤១០ នៃក្រមព្រហ្មទណ្ឌ។

ដោយមានលោក [redacted] បញ្ញារិទ្ធិ អគ្គលេខ ១៤០៧ ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ។

**-ដើមបណ្តឹងរដ្ឋប្បវេណី** ឈ្មោះ [redacted] ម៉េត ភេទស្រី អាយុ៤៤ឆ្នាំ សញ្ជាតិខ្មែរ មានទីលំនៅសព្វថ្ងៃនៅភូមិសិទ្ធិសេរីថ្មី ឃុំគោកមន ស្រុកបន្ទាយអំពិល ខេត្តបន្ទាយមានជ័យ ។

## អំពីអង្គហេតុ

កាលពីថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៧ ស្ថិតនៅភូមិព្រៃទទឹង ឃុំគោកខ្ពស់ ស្រុកបន្ទាយអំពិល ខេត្តឧត្តរមានជ័យ មានករណី ប៉ះពាល់កម្មសិទ្ធិឯកជន និងធ្វើឱ្យខូចខាតដោយចេតនា បង្កឡើងដោយឈ្មោះ [redacted] សោភា ហៅ មុំ ភេទស្រី អាយុ ៤៤ឆ្នាំ បានយកត្រាក់ទ័រភ្ជួរកូនស្វាយរបស់ជនរងគ្រោះឈ្មោះ [redacted] ម៉េត អស់ចំនួន ២០០ដើម ហើយនៅពេលដែលអាជ្ញាធរហាមឃាត់ឈ្មោះ [redacted] សោភា ហៅ មុំ ក៏មិនស្តាប់ដែរ ថែមទាំងចូលយកដីរបស់ជនរងគ្រោះអស់មួយចំនួនថែមទៀត។

**-បានឃើញ** សាលក្រមព្រហ្មទណ្ឌលេខ ០៩ (ក) ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០២១ របស់សាលាដំបូងខេត្តឧត្តរមានជ័យ ដែលបានសម្រេចៈ

១.ផ្តន្ទាទោសលើ ជនជាប់ចោទឈ្មោះ [redacted] សោភា ហៅ មុំ ភេទស្រី អាយុ៤៤ឆ្នាំ ជនជាតិខ្មែរ (សាវតាជាតិខ្មែរ) ដាក់ពន្ធនាគារកំណត់ ០២(ពីរ)ឆ្នាំ តែទោសនេះត្រូវព្យួរទាំងស្រុងក្នុងលក្ខខណ្ឌនៃការព្យួរទោសធម្មតា និងពិន័យជាប្រាក់ចំនួន ៤,០០០,០០០ (បួនលាន)រៀល ដាក់ចូលក្នុងថវិការរដ្ឋចាប់តាំងពីថ្ងៃដែលសាលក្រមនេះចូលជាស្ថាពរតទៅ ។

ពីបទៈ ប៉ះពាល់កម្មសិទ្ធិឯកជន និងធ្វើឱ្យខូចខាតដោយចេតនា ប្រព្រឹត្តនៅចំណុចភូមិព្រៃទទឹង ឃុំគោកខ្ពស់ ស្រុកបន្ទាយអំពិល ខេត្តឧត្តរមានជ័យ កាលពីថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៧ បទល្មើសដែលមានចែងនិងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៤៨, មាត្រា ២៥៣ នៃច្បាប់ភូមិបាល និងមាត្រា ៤១០ នៃក្រមព្រហ្មទណ្ឌ ។

២.ដាក់ជនជាប់ចោទ ឈ្មោះ [redacted] សោភា ហៅ មុំ ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមដានរបស់តុលាការកំណត់ ០៣(បី)ឆ្នាំ តាមមាត្រា ១៧១ នៃក្រមព្រហ្មទណ្ឌ ។

៣.បង្គាប់ឱ្យឈ្មោះ [redacted] សោភា សងសំណងរដ្ឋប្បវេណីថ្លៃខូចខាត និងជម្ងឺចិត្តចំនួន ៥,០០០,០០០ (ប្រាំលាន)រៀល ទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ម៉េត ទាមទារលើសពីនេះបដិសេធចោល ។

៤.សាលក្រមនេះជំនុំជម្រះនៅថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០២០ និងប្រកាសជាសាធារណៈនៅថ្ងៃទី ០៥ ខែមករា ឆ្នាំ២០២១ ចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ម៉េត និងកំបាំងមុខជនជាប់ចោទឈ្មោះ [redacted] សោភា ទុកសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។



Scanned with CamScanner

-បានឃើញ សាលក្រមព្រហ្មទណ្ឌលើបណ្តឹងទាស់លេខ ៥៦(ក) ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០២១ របស់សាលាដំបូងខេត្តឧត្តរមានជ័យ ដែលបានសម្រេច៖

១. ទទួលស្គាល់ពាក្យបណ្តឹងទាស់ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ២០២១ របស់ឈ្មោះ [redacted] សោភា ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់។

២. តម្កល់សាលក្រមកំបាំងមុខលេខ: ០៩ (ក) ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០២១ ទុកជាបានការដដែល តែកែប្រែត្រង់ចំណុចទី១ នៃសាលក្រមកំបាំងមុខ ដោយឱ្យឈ្មោះ [redacted] សោភា ហៅ ម៉ុំ ភេទស្រី អាយុ ៤៤ឆ្នាំ រួចផុតពីបទចោទ។

៣. សាលក្រមនេះជំនុំជម្រះនៅថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២១ ចំពោះមុខជនត្រូវចោទ ឈ្មោះ [redacted] សោភា និងដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ម៉េត ប្រកាសជាសាធារណៈថ្ងៃទី០៣ ខែធ្នូ ឆ្នាំ ២០២១ ។

ទុកសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

-បានឃើញ ពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២១ របស់អយ្យការអមសាលាដំបូងខេត្តឧត្តរមានជ័យ បានប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ៥៦(ក) ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០២១ របស់សាលាដំបូងខេត្តឧត្តរមានជ័យ ដែលបានសម្រេចឱ្យរួចផុតពីបទ ចោទ។

-បានឃើញ ដីកាចាត់តាំងសមាសភាពក្រុមប្រឹក្សាជំនុំជម្រះលេខ ៦៩ ព្រទ.ឧបប/២២ ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០២២ របស់សាលាឧទ្ធរណ៍បាត់ដំបង ។

-បានឃើញ របាយការណ៍រឿងសភាព្រហ្មទណ្ឌ ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២២ របស់សាលាឧទ្ធរណ៍ ។

-បានឃើញ សេចក្តីសន្និដ្ឋាន ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២២ របស់មហាអយ្យការអមសាលាឧទ្ធរណ៍បាត់ដំបង ។

## នាពេលសវនាការ

-ប្រធានក្រុមប្រឹក្សាជំនុំជម្រះអានរបាយការណ៍សង្ខេបរឿង

-ជនជាប់ចោទឈ្មោះ [redacted] សោភា បានឆ្លើយថា៖ ខ្លួនសូមរក្សាចម្លើយដែលបានឆ្លើយនៅសាលាដំបូងខេត្តឧត្តរមានជ័យ ទុកជាបានការដដែល ។ ខ្លួនសូមអះអាងថារឿងនឹងមិនពិត ព្រោះនៅពេលត្រាក់ទ័រភ្ជួរដីគាត់នឹងគឺខ្លួនមិនបាននៅទីនោះទេ ព្រោះខ្លួននៅតែភ្នំពេញទេ ។ ដីខ្លួននឹងធ្វើតាំងពីឆ្នាំ២០១២ ធ្វើមករាចូលប្រហែល ៨ឆ្នាំហើយ ជារៀងរាល់រដូវភ្ជួរដាំដំឡូងរាល់តែឆ្នាំ អញ្ចឹងក្មេងៗដែលចាំនៅទីនោះផ្ទះខ្លួននៅប្រាសាទតាមាន់ដល់ខែដល់ថ្ងៃគេត្រូវភ្ជួរដាំដំឡូងជារៀងរាល់ខែរាល់ឆ្នាំ នៅពេលដល់ពេលប្រមូលផលខ្លួនក៏ទៅលក់ ។ ខ្លួនឃើញមានហ្វេកបុកមួយឈ្មោះ [redacted] ម៉េត ផុសថា ខ្លួននឹងទៅភ្ជួរស្វាយរបស់គាត់ យកដីរបស់គាត់ ដោយហេតុនៅថ្ងៃនឹងខ្លួនក៏មិនបាននៅនឹងដែរ និយាយទៅខ្លួននៅទីនឹងតែមានប្រមូលផលបានខ្លួនទៅលក់ ។ ពេលដែលដាំម្តងៗគឺកូនចៅខ្លួននៅទីនោះគឺដល់ខែដល់ឆ្នាំគេគឺភ្ជួរ ធម្មតា ដោយឡែកនៅពេលថ្ងៃមួយគេបង្ហោះនៅក្នុងហ្វេកបុកថា ខ្លួននឹងទៅភ្ជួរកូនស្វាយគាត់ ខ្លួនក៏



Scanned with CamScanner

ស្រឡាំងកាំង ។ គ្រួសាររបស់ខ្លួនក៏បានចុះទៅមើលក៏បានទៅផ្ទះនៅប្រាសាទតាមាន់នឹងក៏ឃើញកូនស្វាយនឹងប្រហែលមួយចង្កាម ពេលដែលឃើញមួយចង្កាមនឹងអត់ចាប់អារម្មណ៍ទៀត ទាល់តែឃើញភ្លឺស្រែមួយចុះធម្មតាដីនៅទីនោះវាមានវាលស្រែ ទាល់តែអញ្ជើងគ្រួសារខ្លួនពិនិត្យឃើញកូនស្វាយនឹងដាក់មួយទង១ខ្លាចគាត់ចាប់អារម្មណ៍ថា កូនស្វាយមួយចង្កាម១មកដាំចន្លោះលើស្វាយខ្លួនដែលមានរាល់តែដង និយាយទៅស្វាយខ្លួនចូល ៤ឆ្នាំ ប្រមូលហើយវាក្តិបតិច១ហើយ ទាល់តែពេលអញ្ជើងគាត់ថា ស្វាយអីមកដាំនៅលើចន្លោះដីស្វាយដែលមានហើយ ហេតុអ្វីមកចោទប្រកាន់អញ្ជើងព្រោះដីនឹងខ្លួនធ្វើ ៦ ទៅ០៧ឆ្នាំហើយមិនដែលមានអ្វីទេ ហើយកម្មករនៅទីនោះក៏ដឹងដែរថា ខ្លួនធ្វើយូរមកហើយ ។ ខ្លួនសុំបដិសេធទាំងស្រុងចំពោះដែលថាខ្លួនបានទៅភ្ជួរកូនស្វាយរបស់ឈ្មោះ [redacted] ម៉េត ។ ខ្លួនមិនបានដឹងអ្វីទាំងអស់ សូម្បីតែកម្មកររបស់ខ្លួនក៏មិនបានខលមកប្រាប់ខ្លួនដែរ ។ កូនចៅខ្លួនជាអ្នកភ្ជួរ ប៉ុន្តែមិនបានឃើញដើមស្វាយនោះទេ គឺងាប់អស់ហើយ ហើយខ្លួនក៏មិនបានបញ្ជាឱ្យកូនចៅទៅភ្ជួរដែរ ព្រោះដល់ខែដល់ឆ្នាំដីនឹងគឺដាំដំឡូងជារៀងរាល់ឆ្នាំប្រហែលបាន៨ឆ្នាំហើយ ខ្លួនមិនដែលឃើញអ្នកណាមកអះអាងថា ជាកម្មសិទ្ធិរបស់ខ្លួនទេ ទើបតែមានភាគីដើមបណ្តឹងរដ្ឋប្បវេណីមកកាយប្រឡាយធ្វើព្រំនៅដីលើដីទំនាស់ និងអះអាងថា បានដាំដើមស្វាយជាច្រើនដើមនៅលើដីនោះ តែមិនបានឃើញមានដើមស្វាយឡើយ ហើយក៏មិនបានដឹងថា លួចមកដាំតាំងពីពេលណាទេ ហើយថ្ងៃកើតហេតុខ្លួនបានជួលត្រាក់ទ័រមកភ្ជួរតាមរោងស្វាយបានប៉ះពាល់ ឬកិនដើមស្វាយគឺខ្លួនមិនដឹងឡើយ ។ ខ្លួនមិនដែលឃើញមានមេភូមិ ឬក៏ស្រុកហៅទេគឺមិនដែលមាន ។ សំណូមពរក្រុមប្រឹក្សាជំនុំជម្រះមេត្តាសម្រេចតម្កល់សាលក្រមព្រហ្មទណ្ឌទុកជាបានការដដែល ។

-ឈ្មោះ [redacted] កុសល បានឆ្លើយថា៖ ទាក់ទងទៅនឹងរឿងដីនេះអ្វីដែលជាការចោទប្រកាន់របស់ឈ្មោះ [redacted] ម៉េត មានតែប៉ុន្មាននៅក្នុងនេះជាការកុហកទាំងអស់ គ្មានអាជ្ញាធរណាបានមកហៅ គ្មានអាជ្ញាធរណាបានមកកាត់ ប្រសិនបើមានអាជ្ញាធរណាគេមកកាត់កម្មករមិនហ៊ានធ្វើអ្វីទាំងអស់ ប៉ុន្តែវាគ្មាន ដូច្នេះការដែលកាត់កំបាំងមុខនេះជាការមិនពិតទាំងអស់ ហើយអ្វីដែលខ្លួនបានបកស្រាយនៅសាលាដំបូងខេត្តឧត្តរមានជ័យ ។ ដីនេះសូម្បីតែសាមីខ្លួនដែលនិយាយដែលបង្ហោះមកតាមហ្វេកបុកនេះខ្លួនថតចម្លងពីគាត់មកទាំងអស់មកវិញ ហើយនៅក្នុងសវនាការសាលាដំបូងខេត្តឧត្តរមានជ័យ គាត់បានសារភាពថា គាត់បានយកកូនស្វាយតូច១យកទៅដាំប្រឡោះស្វាយដែលមានផ្លែហើយនោះដាំមែន ។ ទំនាស់នឹងគឺកើតឡើងតាំងពីឆ្នាំ ២០១៧ មកម្ល៉េះ គឺតាំងពីឈ្មោ[redacted]ម៉េត បានយកអាអុិចអេស្កាវាទ័រមួយទៅជីកព្រំមួយយ៉ាងធំប្រហែលមួយម៉ែត្រកន្លះបណ្តោយប្រហែលមួយរយម៉ែត្រជាងគារលើដំឡូងដែលខ្លួនដាំស្មើលើជង្គង់ ។ ខ្លួនសូមបញ្ជាក់គឺមិនដែលមានអាជ្ញាធរភូមិណាមកហាមឃាត់ខ្លួននោះទេ ។

-តំណាងមហាអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា៖ ស្នើសុំឱ្យក្រុមប្រឹក្សាជំនុំជម្រះពិនិត្យពិចារណា និងសម្រេចតាមច្បាប់ ។

-ក្រោយពីបានស្តាប់អំណានរបាយការណ៍រឿងព្រហ្មទណ្ឌ

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានពិនិត្យភស្តុតាងនានាក្នុងសំណុំរឿង

-ក្រោយពីបានពិនិត្យ និងពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## សាលាឧទ្ធរណ៍បាត់ដំបង

## យល់ឃើញថា

១-ពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២១ របស់តំណាងអយ្យការអមសាលាដំបូងខេត្តឧត្តរមានជ័យ បានប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ៥៦(ក) ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ ២០២១ របស់សាលាដំបូងខេត្តឧត្តរមានជ័យ ត្រង់ចំណុចដែលបានសម្រេចឱ្យឈ្មោះ[redacted]សោភា រួចផុតពីបទចោទប្រកាន់ ធ្វើឡើងតាមកំណត់ច្បាប់ សាលាឧទ្ធរណ៍បាត់ដំបងអាចទទួលជំនុំជម្រះបាន យោងតាមបញ្ញត្តិមាត្រា ៣៨២ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៤៧ មាត្រា ៣៦៨ មាត្រា ៣៧២ និងមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ និងមាត្រា ៣៧៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

២-នាពេលសវនាការសាលាឧទ្ធរណ៍ជនជាប់ចោទឈ្មោះ[redacted]សោភា បានឆ្លើយបដិសេធថា ខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់ទេ ដីទំនាស់នេះខ្លួនបានកាន់កាប់ និងបានដាំដើមស្វាយមានរយៈពេលប្រហែលជិត ០៨ឆ្នាំ មកហើយ ដោយគ្មានជនណាមកអះអាងថាជាកម្មសិទ្ធិរបស់ខ្លួនទេ ទើបតែមានភាគីដើមបណ្តឹងរដ្ឋប្បវេណីមកកាយប្រឡាយធ្វើព្រំនៅលើដីទំនាស់ និងអះអាងថា បានដាំដើមស្វាយជាច្រើនដើមនៅលើដីនោះ តែមិនបានឃើញមានដើមស្វាយឡើយ ហើយក៏មិនបានដឹងថា លួចមកដាំតាំងពីពេលណាទេ ហើយថ្ងៃកើតហេតុខ្លួនបានជួលត្រាក់ទ័រមកភ្ជួរតាមរោងស្វាយបានប៉ះពាល់ ឬកិនដើមស្វាយគឺខ្លួនមិនដឹងឡើយ ។ ត្រង់ចំណុចនេះ ផ្អែកតាមចម្លើយជនជាប់ចោទនេះមានភាពស៊ីសង្វាក់ទៅនឹងចម្លើយសាក្សីឈ្មោះ[redacted]កុសល បានឆ្លើយនាពេលសវនាការនេះថាឈ្មោះ[redacted] សោភា មិនបានជួលត្រាក់ទ័រមកភ្ជួរដីទំនាស់នេះ និងគ្មានឃើញអាជ្ញាធរបានហាមឃាត់ឡើយ ហើយស្វាយដែលដើមបណ្តឹងរដ្ឋប្បវេណីអះអាងថា បានដាំនោះមិនមានទេ ផ្ទុយមកវិញ មានតែដើមបណ្តឹងរដ្ឋប្បវេណីទេដែលបានជីកប្រឡាយព្រំនៅលើដីទំនាស់នាំឱ្យខូចដំឡូងមីរបស់ខ្លួន ។

៣-តាមចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដែលបានឆ្លើយនាពេលសវនាការសាលាដំបូងលើកទី១ថា ឈ្មោះ[redacted]សោភា បានដាំដំឡូងមីនៅលើដីរបស់ខ្លួនចំនួន ០៣ហិចតា និងបានដកដំឡូងមីនៅឆ្នាំ ២០១៧ ហើយក្រោយមកខ្លួនបានយកកូនស្វាយចំនួន ២០០ ដើមទៅដាំលើដីនោះបានត្រឹម៣ ថ្ងៃ ទៅ៤ថ្ងៃ ស្រាប់តែឈ្មោះ[redacted]សោភា បានយកត្រាក់ទ័រមកភ្ជួរកូនស្វាយខ្លួនចោលអស់ ។ ប៉ុន្តែ



Scanned with CamScanner

នៅដំណាក់កាលនៃការជំនុំជម្រះរបស់សាលាដំបូងលើបណ្តឹងទាស់របស់ជនជាប់ចោទនោះ បែរជាដើមបណ្តឹងរដ្ឋប្បវេណីបានឆ្លើយថា ខ្លួនបានយកកូនស្វាយទៅដាំនៅចន្លោះដើមស្វាយដែលមានកន្លងមក ។ ដូច្នេះ អង្គហេតុនៃការចោទប្រកាន់ថា ជនជាប់ចោទបានបំផ្លិចបំផ្លាញកូនស្វាយរបស់ដើមបណ្តឹងរដ្ឋប្បវេណីចំនួន ២០០ដើម នោះ ដោយផ្អែកលើចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីគឺគ្មានភាពច្បាស់លាស់ ហើយគ្មានភស្តុតាងគាំទ្រមកបញ្ជាក់ឱ្យឃើញច្បាស់ថា ជនជាប់ចោទបានប្រព្រឹត្តដូចការចោទប្រកាន់ទេ ។

៤-ការចោទប្រកាន់ពីបទ ប៉ះពាល់កម្មសិទ្ធិឯកជននេះឃើញថា តាមការអះអាងបញ្ជាក់ និងភស្តុតាងរបស់ភាគីទាំងពីរ គឺដីទំនាស់នេះមិនទាន់មានប័ណ្ណកម្មសិទ្ធិនៅឡើយ ដោយភាគីទាំងសងខាងបានអះអាងពីការកាន់កាប់ និងបានដាំដំណាំរៀងៗខ្លួននៅលើដីនេះ ហើយមិនទាន់មានសេចក្តីសម្រេចស្ថាពរបញ្ជាក់ថា ជាកម្មសិទ្ធរបស់ភាគីណាមួយឡើយ ។ ដូច្នេះការចោទប្រកាន់ពីបទល្មើសនេះមិនមានធាតុផ្សំបទល្មើសគ្រប់គ្រាន់ ដែលអាចដាក់បន្ទុកលើជនជាប់ចោទបាននោះទេ ។

៥-តំណាងមហាអយ្យការបានសន្និដ្ឋានថា សូមមកឱ្យក្រុមប្រឹក្សាជំនុំជម្រះពិនិត្យ ពិចារណា និងសម្រេចតាមច្បាប់ ។ សេចក្តីសន្និដ្ឋាននេះសភាព្រហ្មទណ្ឌបានពិចារណាដូចមានក្នុងសំអាងហេតុខាងលើនេះ ។

៦-សំដីចុងក្រោយរបស់ជនជាប់ចោទបានសំណូមពរថា សូមសម្រេចឱ្យខ្លួនរួចផុតពីបទចោទប្រកាន់ ។ ចំពោះសំណូមពរនេះ សភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍ទទួលយកមកពិចារណា និងសម្រេចបានដូចការយល់ឃើញខាងលើ ។

៧-គ្មានភស្តុតាង និងពិរុទ្ធភាពគ្រប់គ្រាន់ដាក់បន្ទុកលើជនជាប់ចោទឈ្មោះ [redacted] សោភា ហៅ មុំ ភេទស្រី អាយុ៤៤ឆ្នាំ ដែលមានសាវតាជាតិដូចខាងលើពីបទ៖ ប៉ះពាល់កម្មសិទ្ធិឯកជន និងធ្វើឱ្យខូចខាតដោយចេតនា ប្រព្រឹត្តនៅភូមិព្រៃទទឹង ឃុំគោកខ្ពស់ ស្រុកបន្ទាយអំពិល ខេត្តឧត្តរមានជ័យ កាលពីថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៧ បទល្មើសដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៤៨ មាត្រា ២៥៣ នៃច្បាប់ភូមិបាល និងមាត្រា ៤១០ នៃក្រមព្រហ្មទណ្ឌ ។

៨-សាលាដំបូងខេត្តឧត្តរមានជ័យបានយល់ឃើញក្នុងសំអាងហេតុ គ្មានភស្តុតាង និងពិរុទ្ធភាពគ្រប់គ្រាន់ដាក់បន្ទុកលើជនជាប់ចោទនោះជាការត្រឹមត្រូវហើយ ។ ប៉ុន្តែផ្ទុយមកវិញសាលាដំបូងបានសម្រេចត្រង់ចំណុច ២ ដូចក្នុងសាលក្រមព្រហ្មទណ្ឌលេខ ៥៦(ក) ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០២១ ដោយបានតម្កល់សាលក្រមកំបាំងមុខលេខ ០៩ (ក) ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០២១ ទុកជាបានការដដែល ហើយបានសម្រេចឱ្យជនជាប់ចោទរូបនេះរួចខ្លួនពីបទចោទនោះមិនត្រឹមត្រូវឡើយ ។ ដូច្នេះ គប្បីសាលាដំបូងសម្រេចបដិសេធសាលក្រមកំបាំងមុខនេះចោល ហើយសម្រេចឱ្យជនជាប់ចោទរួចខ្លួនពីបទចោទប្រកាន់ ។



Scanned with CamScanner

៩-ផ្អែកតាមចម្លើយរបស់ជនជាប់ចោទដែលបានឆ្លើយគ្រប់ដំណាក់កាលនៃនីតិវិធី ចម្លើយសាក្សី ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី និងភស្តុតាងជាឯកសារគឺផ្ទុយពីការប្តឹងចោទប្រកាន់របស់ដើមបណ្តឹងរដ្ឋប្បវេណី និងមូលដ្ឋាននៃការចោទប្រកាន់តាមបន្ទុកនៃភស្តុតាងនានាដែលតំណាងមហាអយ្យការបានលើកឡើង ដែលនាំឱ្យសភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍យល់ឃើញថា ជនជាប់ចោទបានឆ្លើយដោះសារគឺមានភស្តុតាងគ្រប់គ្រាន់ដែលបញ្ជាក់ថា ជនជាប់ចោទគ្មានចេតនាប្រព្រឹត្ត និងគ្មានកំហុសឡើយ ។ ត្រង់នេះការបញ្ជាក់ថា គ្មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើជនជាប់ចោទនោះទេ ដោយផ្អែកតាមមាត្រា ៣២១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ មានខ្លឹមសារជាគោលការណ៍ថា តុលាការសំអាងនៅក្នុងសេចក្តីសម្រេចរបស់ខ្លួនតែទៅលើភស្តុតាងដែលមានក្នុងសំណុំរឿង ឬដែលត្រូវគេយកមកបង្ហាញនៅពេលសវនាការប៉ុណ្ណោះ ហើយមាត្រា ៣៥៧ កថាខណ្ឌទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌបានកំណត់ថា អង្គហេតុត្រូវតែច្បាស់លាស់ និងគ្មានការសង្ស័យ ។ ដូច្នេះផ្អែកតាមមាត្រា ៣៨ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងមាត្រា ៣៥១ នៃក្រមនីតិវិធីព្រហ្មទណ្ឌចែងថា វិមតិសង្ស័យត្រូវតែបានជាប្រយោជន៍ដល់ជនជាប់ចោទជានិច្ច ។

១០-បណ្តឹងឧទ្ធរណ៍របស់តំណាងអយ្យការអមសាលាដំបូងខេត្តឧត្តរមានជ័យ ពុំមានមូលហេតុនៃបណ្តឹងឧទ្ធរណ៍ និងភស្តុតាងគាំទ្រដែលអាចឱ្យសាលាឧទ្ធរណ៍បដិសេធសាលក្រមរបស់សាលាដំបូងបានឡើយ ។ ការប្តឹងឧទ្ធរណ៍នេះនៅតែជាប្រយោជន៍បានដល់ជនជាប់ចោទដដែល ។

១១-សាលក្រមព្រហ្មទណ្ឌលេខ ៥៦(ក) ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០២១ របស់សាលាដំបូងខេត្តឧត្តរមានជ័យ ដែលសម្រេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវខ្លះ និងមិនត្រឹមត្រូវខ្លះ ។ ដូច្នេះ គប្បីតម្កល់សេចក្តីសម្រេចចំណុច ១ ទុកជាបានការ ហើយសេចក្តីសម្រេចចំណុច ២ ដែលជាចំណុចខ្វះខាតត្រូវសម្រេចឡើងវិញ ដូចការយល់ឃើញខាងលើ ។

## ហេតុដូច្នេះ
## វិនិច្ឆ័យសេចក្តី

១-ទទួលពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២១ របស់តំណាងអយ្យការអមសាលាដំបូងខេត្តឧត្តរមានជ័យ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ៥៦(ក) ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០២២ របស់សាលាដំបូងខេត្តឧត្តរមានជ័យ ទុកជាបានការដដែល ដោយគ្រាន់តែសម្រេចឡើងវិញនូវសេចក្តីសម្រេចចំណុច ២ ដូចខាងក្រោម៖

បដិសេធសាលក្រមកំបាំងមុខលេខ ០៩(ក) ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០២១ របស់សាលាដំបូងខេត្តឧត្តរមានជ័យ ចោល ដោយសម្រេចឱ្យជនជាប់ចោទឈ្មោះ [redacted] សោភា រួចខ្លួនពីការ



Scanned with CamScanner

ចោទប្រកាន់ពីបទ៖ ប៉ះពាល់កម្មសិទ្ធិឯកជន និងធ្វើឱ្យខូចខាតដោយចេតនា ប្រព្រឹត្តនៅចំណុចភូមិព្រៃទទឹង ឃុំគោកខ្ពស់ ស្រុកបន្ទាយអំពិល ខេត្តឧត្តរមានជ័យ កាលពីថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៧ បទល្មើសដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៤៨ និងមាត្រា ២៥៣ នៃច្បាប់ភូមិបាល និងមាត្រា ៤១០ នៃក្រមព្រហ្មទណ្ឌ ។

សាលដីកានេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០២២ និងប្រកាសជាសាធារណៈនៅថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២២ ចំពោះមុខជនជាប់ចោទឈ្មោះ[redacted]សោភា ដោយកំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ហេង ម៉េត ។

រក្សាសិទ្ធិប្តឹងតវ៉ាតាមកំណត់ច្បាប់ ។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|---|
| ហត្ថលេខា | ហត្ថលេខា | ហត្ថលេខា | ហត្ថលេខា |
| [redacted] | [redacted] | [redacted] | [redacted] |

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃព្រហស្បតិ៍ ៤កើត ខែអស្សុជ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

សាលាឧទ្ធរណ៍បាត់ដំបង, ថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២២

**បានឃើញ**

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]

**ក្រឡាបញ្ជី**

[redacted]